**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ០១២៤ ព.ណ.ពសម

ថ្ងៃសុក្រ ៦កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០២១

## ជម្រាបមក
## លោក/លោកស្រីប្រធាន ក្រុមហ៊ុន តូយ៉ូតា (ខេមបូឌា)

**កម្មវត្ថុ:** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើយានយន្ត និងគ្រឿងបន្លាស់ម៉ាក "RAIZE", "PRIUS", "COROLLA CROSS", "ALPHARD", "RUSH", "WIGO", "VIOS", "TOYOTA AVANZA", "TOYOTA MAJESTY", "TOYOTA INNOVA", "RAV4", "LANDCRUISER PRADO" និង "FORTUNER" ដែលមានម៉ូដែលភ្ជាប់មកជាមួយ ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **តូយ៉ូតា (ខេមបូឌា)**។

**យោង:**- មាត្រា ៣ និងមាត្រា ១១ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន **តូយ៉ូតា (ខេមបូឌា)** ចុះថ្ងៃទី ២៦ ខែវិច្ឆកា ឆ្នាំ២០២០
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន TOYOTA MOTOR CORPORATION ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០២០
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៧៦២០៨/២០ ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០២០
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៦០៧១៤/១៦ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៦
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៧៣៥៥១/១៩ ចុះថ្ងៃទី ០៨ ខែតុលា ឆ្នាំ ២០១៩
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៥២០៧៤/១៤ ចុះថ្ងៃទី ០៤ ខែសីហា ឆ្នាំ ២០១៤
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៦១៩០៨/១៦ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០១៦
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៦៤៧៧៦/១៧ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៧
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៥៨៦០៥/១៦ ចុះថ្ងៃទី ០៧ ខែមីនា ឆ្នាំ ២០១៦
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៥០៧៩៥/១៤ ចុះថ្ងៃទី ០៧ ខែឧសភា ឆ្នាំ ២០១៤
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៧៩៦១៤/២០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០២០
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/១៩០៧៤/០៤ ចុះថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០១៣
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/៣០២០៣/០៩ ចុះថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០១៧
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/៩០៣៧/៩៧ ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៧
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/១៩០១០/០៣ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០១៣។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើយានយន្ត និងគ្រឿងបន្លាស់ពាក់ម៉ាកខាងលើក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **តូយ៉ូតា (ខេមបូឌា)** ដែលទទួលបានពីក្រុមហ៊ុន TOYOTA MOTOR CORPORATION ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខដែលក្រសួងបានតម្កល់ទុករួចហើយ។

លិខិតកត់ត្រា និងតម្កល់សិទ្ធិផ្តាច់មុខនេះមានសុពលភាពត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២២ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិមុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន TOYOTA MOTOR CORPORATION ដែលជាម្ចាស់ម៉ាក។

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

ចាប់ពីក្រោយរយៈពេល ៩០(កៅសិប)ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខនេះ អ្នកទទួលសិទ្ធិស្របច្បាប់មានសិទ្ធិប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការរារាំងទំនិញដែលនាំចូលស្របគ្នា។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវបោះពុម្ពផ្សាយលិខិតកត់ត្រានេះក្នុងទំព័រខាងមុខសារព័ត៌មានល្បីៗភ្លាមយ៉ាងតិចចំនួន ៣(បី) លេខជាប់ៗគ្នា និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវនូវលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**អ៊ុក-ប្រូជា**

***ចម្លងជូន:***

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី **ស ខេង***
- *ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ*
- *អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ - កាលប្បវត្តិ*

# បញ្ជី

## ម៉ូដែលភ្ជាប់នឹងលិខិតកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល នឹងចែកចាយផ្តាច់មុខ

## រថយន្តម៉ាក “TOYOTA”

| ល.រ | ឈ្មោះ ម៉ូដែល |
|---|---|
| **រថយន្ត** | |
| 1 | LAND CRUISER PRADO |
| 2 | RAV4 |
| 3 | FORTUNER |
| 4 | AVANZA |
| 5 | VIOS |
| 6 | WIGO |
| 7 | RUSH |
| 8 | INNOVA |
| 9 | ALPHARD |
| 10 | COROLLA CROSS |
| 11 | PRIUS |
| 12 | RAIZE |
| 13 | MAJESTY |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
អគ្គនាយកដ្ឋាន សេវាពាណិជ្ជកម្ម
នាយកដ្ឋានកម្មសិទ្ធិបញ្ញា
ការិយាល័យក្រោយចុះបញ្ជីម៉ាកពាណិជ្ជកម្ម

# កំណត់បង្ហាញ
# ការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ

- **កម្មវត្ថុ៖** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើរថយន្តម៉ាក "COROLLA", "HIACE", "COASTER", "LANDCRUISER", "HILUX", "CAMRY", "RAIZE", "PRIUS", "COROLLA CROSS", "ALPHARD", "RUSH", "WIGO", "VIOS", "TOYOTA AVANZA", "TOYOTA MAJESTY", "TOYOTA INNOVA", "RAV4", "LANDCRUISER PRADO" និង "FORTUNER"
- **អ្នកស្នើសុំ៖ ក្រុមហ៊ុន តូយ៉ូតា (ខេមបូឌា)**
- **យោង៖** គោលការណ៍ឯកភាព**ឯកឧត្តមរដ្ឋមន្ត្រី** ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០២០

ដោយមានចំណារឯកភាពឯកឧត្តមរដ្ឋមន្ត្រី គួរធ្វើការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើម៉ាកជូន។

**ប្រធានការិយាល័យក្រោយចុះបញ្ជីម៉ាកពាណិជ្ជកម្ម**

06.01.2021

**លុយ សុផល្លា**

| **យោបល់ឯកឧត្តមអគ្គនាយក** | **យោបល់អនុប្រធាននាយកដ្ឋាន** |
|---|---|
| 19-01-2021 | **គោរពជូន**<br>យោងមាត្រា៣ និង១១ នៃច្បាប់ម៉ាក និងឯកសារតម្រូវដែលបានដាក់មកនាងខ្ញុំ/ខ្ញុំបាទយល់ឃើញថា ក្រសួងអាចអនុញ្ញាតឲ្យធ្វើការ កត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខបាន តាមការស្នើសុំ ។<br>សូមលោកប្រធាន ឯកឧត្តមអគ្គនាយក ឯកឧត្តម/លោកជំទាវ រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ មេត្តាពិនិត្យ និងសម្រេច តាមការ គួរ។<br>06.01.20 |
| **យោបល់របស់ឯកឧត្តម/លោកជំទាវ រដ្ឋលេខាធិការ ឬ អនុរដ្ឋលេខាធិការ** | **យោបល់ប្រធាននាយកដ្ឋាន** |
| ឯកភាព<br>**រដ្ឋលេខាធិការ**<br>19/01/21<br>អ៊ុក-ប្រជា | **យោងគោលការណ៍ឯកភាពរបស់ ឯកឧត្តមរដ្ឋមន្ត្រី៖**.............<br>សូម ឯកឧត្តមអគ្គនាយក ឯកឧត្តម/លោកជំទាវ រដ្ឋលេខាធិការ ឬ អនុរដ្ឋលេខាធិការ មេត្តាពិនិត្យ និងសម្រេច ដោយក្តីអនុគ្រោះ។<br>19/01/2021 |